ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៣៨...ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក រួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២- | ឯកឧត្តម **នុត សារអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣- | ឯកឧត្តម **ឆាន់ សាផាន់** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

www.pheakdeylaw.com

៤- ឯកឧត្តម **តឹករ៉េត សំរេច** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥- ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៦- ឯកឧត្តម **ពេជ អន្ត** សមាជិកបម្រុង នៃក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

៧- ឯកឧត្តម **ឈុន ស៊ីរុន** អភិបាលខេត្តកណ្តាល សមាជិក ។

**ប្រការ ២ :** ប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក
- ធ្វើការបូកសរុប វាយតម្លៃ ពីផលប៉ះពាល់ ដែលបណ្តាលមកពីសកម្មភាពអសកម្មទាំងនោះ
- លើកវិធានការជូនសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ពិនិត្យ និងសម្រេច ។

**ប្រការ ៣ :** ប្រតិភូចុះពិនិត្យជាក់ស្តែង លើសកម្មភាពចាក់ដីលុបអាងទឹកតាមោក និងសកម្មភាពអសកម្មនានា ដែលមាននៅក្នុងអាងទឹកតាមោក ត្រូវចូលរួមប្រជុំ និងចុះពិនិត្យការងារជាក់ស្តែង តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com